*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

រឿងក្ដីលេខ៖ ២៣៤ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៩

សញ្ញាណនៃរឿងក្ដី ៖ ទាមទារប្រាក់

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៩

សាលក្រមលេខ ៖ ១៩ ជ

ថ្ងៃប្រកាសសាលក្រម ៖ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកំពង់ធំ

បានចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ ៖

**ដើមចោទ**

-ឈ្មោះ តដ ជាតំណាងឲ្យគ្រឹះស្ថាន ជ ដែលមានទីស្នាក់ការអាគារលេខ រាជធានីភ្នំពេញ ។

**សហចុងចម្លើយ**

-ឈ្មោះ ច១ ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ និងប្ដីឈ្មោះ ច១-២ អាយុ៣៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិ ខេត្តកំពង់ធំ ។

-ឈ្មោះ ច២ អាយុ៣៥ឆ្នាំ និងប្ដីឈ្មោះ ច២-២ អាយុ៣៥ឆ្នាំ រស់នៅភូមិ ខេត្តកំពង់ធំ ។

**អង្គហេតុ និង ចំណុចវិវាទ**

**១.ការទាមទារ**

១-ឲ្យឈ្មោះ ច១ និងប្ដីឈ្មោះ ច១-២ រួមទាំងឈ្មោះ ច២ និងប្ដីឈ្មោះ ច២-២ សងប្រាក់ដើមដែលនៅជំពាក់សរុប ចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន)។

២-ការប្រាក់ ចំនួន ១,៨០ % (មួយក្បៀសប៉ែតសិបភាគរយ) ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ រហូតដល់សងរួច។

៣-ការប្រាក់ពិន័យ ៣% (បីភាគរយ) លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២០ (ករណីហួសកាលកំណត់សងចុងក្រោយ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២០ រហូតដល់សងរួច) ។

៤-ទាមទារថ្លៃខាតបង់ពេលវេលា ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៦-សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ត្រង់ចំណុចទី ១ លើប្រាក់ដើម ។

*កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

## ២.ការពន្យល់ត្រួសៗអំពីរឿងក្តី៖

២.១ ក្នុងរឿងក្តីនេះ ដើមចោទ និងចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយគ្រឹះស្ថាន ដ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ខ្ចីប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដោយបានព្រមព្រៀងគ្នាអនុវត្តនូវអត្រាការប្រាក់ ១,៨០% (មួយក្បៀសប៉ែតសិបភាគរយ)ក្នុងមួយខែ ប្រាក់ពិន័យ ៣% (បីភាគរយ) ក្នុងមួយខែ (អនុវត្តក្នុងករណីហួសកាលកំណត់សងចុងក្រោយ នៅថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ២០២០) ខ្ចីក្នុងរយៈពេល ៦០ ខែ ដោយបង់សងការប្រាក់ និងប្រាក់ដើមរាល់ខែតាមតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥។ សម្រាប់ការខ្ចីប្រាក់នេះឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ បានចុះកិច្ចសន្យាធានាសងបំណុលជំនួសឈ្មោះ ច១ និងឈ្មោះ ច១-២ ។ ចុងចម្លើយបានសងប្រាក់ដើមទៅដើមចោទបានចំនួន ៤.០១០,៦២ (បួនពាន់ដប់ដុល្លារអាមេរិក និងហុកសិបពីរសេន) នៅសល់ប្រាក់ដើមចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) ចុងចម្លើយបានខកខានមិនបានសងទៅអោយដើមចោទ ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ រហូតមកដល់បច្ចុប្បន្ន ។

២.២ អង្គហេតុដែលគ្មានវិវាទ៖

- ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានអវត្តមាននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ តែបានអោយម្តាយឈ្មោះ [redacted] ចូលរួមជំនួស។
- ដើមចោទ និង ចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ ទទួលស្គាល់កិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ដោយខ្ចីប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក អត្រាការប្រាក់ ១.៨០ % (មួយក្បៀសប៉ែតសិបភាគរយ) ក្នុងមួយខែ ។
- ចុងចម្លើយទទួលស្គាល់ថាបានទទួលប្រាក់ដើមគ្រប់ចំនួនតាមកិច្ចសន្យាខ្ចីបរិភោគ។
- ចុងចម្លើយទទួលស្គាល់ថា អំឡុងពេលដែលត្រូវសងបានកន្លងផុត តែចុងចម្លើយខកខានមិនបានបង់សងទៅដើមចោទវិញទេ ។
- ចុងចម្លើយទទួលស្គាល់ថានៅជំពាក់ប្រាក់ដើមចោទ ចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) និងការប្រាក់ ១,៨០ (មួយក្បៀសប៉ែតសិប) ភាគរយ ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៧។
- ចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ ទទួលស្គាល់កិច្ចសន្យាធានាជាមួយដើមចោទ ។

### ២.៣ ចំណុចវិវាទ

- គ្មាន ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរគូភាគី និង ការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

1. ចុងចម្លើយឈ្មោះ ច១ និង ឈ្មោះ ច១-២ បានអវត្តមាននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ តែបានអោយម្តាយឈ្មោះ [redacted] ចូលរួមជំនួស។ យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការ[illegible] ថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទទាក់ទងនឹងអង្គហេតុ។

2. ដើមចោទអះអាងថា ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានចុះកិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ដោយខ្ចីប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក អត្រាការប្រាក់ ១,៨០ % (មួយក្បៀសប៉ែនសិបភាគរយ) ក្នុងមួយខែ តែបានបង់សងប្រាក់ដើមខ្លះហើយ គឺនៅសល់ជំពាក់ប្រាក់ដើមចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) ។ តុលាការយល់ឃើញថា កិច្ចសន្យានេះ ធ្វើឡើងដោយមានការព្រមព្រៀង និង មានផ្តិតស្នាមមេដៃរបស់ភាគីទាំងពីរ គឺមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៥៧៩ និង មាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី ដូចនេះគប្បីតុលាការទទួលស្គាល់ ។

3. ចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ បានទទួលស្គាល់ថា ពួកខ្លួនពិតជានៅជំពាក់ប្រាក់គ្រឹះស្ថាន ដ ចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) តែពួកខ្លួនពុំទាន់មានលទ្ធភាពសងទាំងអស់ទេ។

4. តាមសំអាងហេតុខាងលើនេះ បានបង្ហាញពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ដើមចោទមានលើចុងចម្លើយលើប្រាក់ដើមចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) ដូចនេះ ការទាមទារប្រាក់ដើមរបស់ដើមចោទ តុលាការគប្បីទទួលស្គាល់ ។

5. កិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទនិងចុងចម្លើយបានកំណត់អំពីការប្រាក់ចំនួន ១,៨% (មួយក្បៀសប្រាំបី) ភាគរយ ក្នុងមួយខែ គឺស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧.០៩-២១៣ប្រក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ដូចនេះតុលាការគប្បីទទួលស្គាល់ការទាមទារការប្រាក់នេះ ។

6. ដើមចោទទាមទារប្រាក់ពិន័យ ចំនួន ៣ % ភាគរយ ក្នុងមួយខែ ក្នុងករណីបង់សងប្រាក់ជំពាក់យឺតយ៉ាវក្រោយថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២០ តាមកិច្ចន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ។ ដោយកាលបរិច្ឆេទដែលកំណត់តាមកិច្ចសន្យាខ្ចីបរិភោគសម្រាប់ការប្រាក់ពិន័យមិនទាន់មកដល់ ដូចនេះតុលាការគប្បីច្រានចោលការទាមទាររបស់ដើមចោទលើការទាមទារប្រាក់ពិន័យនេះ ។

7. ចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ បានទទួលស្គាល់ថាខ្លួនបានព្រមព្រៀងផ្តិតមេដៃលើកិច្ចសន្យាធានាជាមួយដើមចោទ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ។ កិច្ចសន្យាធានានេះមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៩០០ នៃក្រមរដ្ឋប្បវេណីតុលាការគប្បីទទួលស្គាល់ ។ ដូចនេះចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ កើតមាននូវកាតព្វកិច្ចសងបំណុលទៅដើមចោទ ស្របតាមមាត្រា ៩០៣ នៃក្រមរដ្ឋប្បវេណី ។

8. ដោយការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយជាកូនបំណុល ដើមចោទអាចទាមទារសំណងនៃការខូចខាតបាន តាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី។ តុលាការគប្បីសម្រេចអំពីសំណងការខូចខាតនេះដោយពិចារណាទៅតាមស្ថានភាពជាក់ស្តែង ។

9. បំណុលដែលចុងចម្លើយជំពាក់ដើមចោទគឺមានភ្ជាប់នឹងការប្រាក់ ដូចនេះដើម្បីចៀសវាងការអូសបន្លាយពេលវេលានាំឲ្យកើនការប្រាក់ច្រើននាំឲ្យខាតបង់ប្រយោជន៍ដល់ចុងចម្លើយ ហើយការអូសបន្លាយពេលវេលានេះដែរក៏នាំឲ្យខាតបង់ផលប្រយោជន៍របស់ដើមចោទដែលជាគ្រឹះស្ថាន ដ ក្នុងការប្រើប្រាស់ប្រាក់នេះក្នុងជំនួញរបស់ខ្លួន ។ តាមហេតុផលនេះ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់ដើមចោទ ដែលសុំឲ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ននូវសាលក្រមនេះ តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

10. យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

១. ឲ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច១-២ បង់សងប្រាក់ជំពាក់ប្រាក់ដើមចំនួន ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) ទៅឲ្យគ្រឹះស្ថានមីក្រូ

ដ

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

២. ឲ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច១-២ បង់សងការប្រាក់តាមអត្រា ១,៨០ % (មួយក្បៀសប៉ែតសិបភាគរយ) ក្នុងមួយខែ គិតទៅលើប្រាក់ដើម ៥.៩៨៩,៣៨ (ប្រាំពាន់ប្រាំបួនរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបប្រាំបីសេន) គិតពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ រហូតដល់សង់គ្រប់ចំនួន ទៅឲ្យគ្រឹះស្ថាន ដ ។

៣. ប្រានចោលការទាមទាររបស់ដើមចោទលើការទាមទារប្រាក់ពិន័យ ។

៤.ឲ្យចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច១-២ បង់សំណងការខូចខាត ចំនួន ៤.០០០.០០០ (បួនលាន)រៀល ទៅឲ្យគ្រឹះស្ថាន ដ ។

៥.ឲ្យចុងចម្លើយឈ្មោះ ច២ និងឈ្មោះ ច២-២ បង់សងប្រាក់ជំពាក់ប្រាក់ដើម ការប្រាក់ និងប្រាក់សំណងការខូចខាត ទៅអោយគ្រឹះស្ថាន ដ រហូតគ្រប់ចំនួន ក្នុងករណីចុងចម្លើយឈ្មោះ ច១ និងឈ្មោះ ច១-២ មិនអាចអនុវត្តកាតព្វកិច្ចចម្បងដូចមានចែងក្នុងចំណុច ទី ១ ទី ២ និងទី ៤ នៃសេចក្តីសម្រេចខាងលើនេះ បានគ្រប់ចំនួននោះ ។

៦. ចំណុចទី១ នៃសេចក្តីសម្រេចខាងលើនេះ អាចអនុវត្តជាបណ្តោះអាសន្នបាន ។

៧. រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់រួចហើយ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ថ្ងៃពុធ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ធំ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៩

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ **ហោខ ចន្ទស៊ីបូរិន**

---

បានឃើញ

**ចៅក្រម**

ហោខ ចន្ទស៊ីបូរិន

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ធំ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**